ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**សូមគោរពជូន**

**លោកជំទាវរដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

*ជាទីគោរព។*

**<u>កម្មវត្ថុ:</u>** របាយការណ៍លទ្ធផលចូលរួមទស្សនកិច្ចសិក្សាស្តីអំពី ការគ្រប់គ្រងមជ្ឈមណ្ឌលជនរងគ្រោះដោយអំពើជួញដូរមនុស្សរយៈពេល០៦ថ្ងៃ(ចាប់ពីថ្ងៃទី០១-០៦ ខែធ្នូ ឆ្នាំ ២០១៩) នៅទីក្រុងបាងកក ប្រទេសថៃ ។

**<u>យោង:</u>** លិខិតលេខ ១១៩៥ស.អ.យ ចុះថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០១៩ របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

-ចំណារ " ឯកភាព " របស់ **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** ចុះថ្ងៃទី ២៨ /១១/ ២០១៩។

តបតាមកម្មវត្ថុ និងយោងខាងលើ នាងខ្ញុំសូមគោរពជំរាបជូន **លោកជំទាវ** មេត្តាជ្រាបថា ដោយបានទទួលការអនុញ្ញាតិពី **លោកជំទាវ** កាលពីថ្ងៃទី០១ ដល់ថ្ងៃទី ០៦ ខែធ្នូ ឆ្នាំ២០១៩ នាងខ្ញុំ បានទៅចូលរួមធ្វើទស្សនកិច្ចសិក្សាស្តីអំពី ការគ្រប់គ្រងមជ្ឈមណ្ឌលថៃទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស នៅទីក្រុងបាងកក ប្រទេសថៃ ក្រោមការដឹកនាំដោយ **ឯកឧត្តម ញឹក សុវណ្ណារ៉ា រដ្ឋលេខាធិការក្រសួង សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា** និងជាប្រធានគណៈប្រតិភូ។

I-**សមាសភាពចូលរួម**:

សរុប ១៦ នាក់ (ស្រី០៦នាក់) មកពី: ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ ក្រសួងសុខាភិបាល ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងតំណាងរដ្ឋបាលសាលាខេត្តបន្ទាយមានជ័យ។

II-**សមាសភាពគណៈអធិបតី**:

**ភាគីកម្ពុជា:** ឯកឧត្តម **ញឹក សុវណ្ណារ៉ា** រដ្ឋលេខាធិការក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

**ភាគីថៃ:**តំណាងក្រសួងអភិវឌ្ឍន៍សង្គម និងសន្តិសុខមនុស្ស និងប្រធាននាយកដ្ឋានរបស់ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិថៃ(TICA)នៃក្រសួងការបរទេស។

III-**សកម្មភាពដែលបានប្រព្រឹត្តទៅតាមកម្មវិធីដែលបានគ្រោងទុក មានដូចខាងក្រោម៖**

**<u>ថ្ងៃទី០២ខែធ្នូឆ្នាំ២០១៩</u>**

ដំណើរទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌលគ្រប់គ្រងសុវត្ថិភាពជនរងគ្រោះដោយអំពើជួញដូរមនុស្ស( បានក្រេតត្រាក់កាន )ខេត្តនន្ទថៈបុរី។

- កិច្ចស្វាគមន៍របស់ភាគីថៃ និងណែនាំសមាសភាពចូលរួមរៀងខ្លួន ទាំងភាគីកម្ពុជា និងភាគីថៃ
- ទស្សនាវីឌីអូអំពីសកម្មភាពមជ្ឈមណ្ឌលគ្រប់គ្រងសុវត្ថិភាព

- ទស្សនកិច្ចសិក្សាតាមផ្នែកជំនាញនីមួយៗនៃមជ្ឈមណ្ឌល(បានក្រេតត្រាក់កាន)រួមមានជំនាញចំនួន ០៦ដូចជាៈ កាត់ដេរ កែសម្ផស្ស ម៉ាស្សា សិប្បកម្ម ធ្វើនំ និងតម្បាញ។
- កិច្ចស្វាគមន៍ និងការទទួលទានអាហារពេលល្ងាច ដែលរៀបចំដោយទីភ្នាក់ងារTICAក្រសួងការបរទេសថៃ។

**ថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៩**

**ដំណើរទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌលទទួលក្មេងប្រុស និងយុវជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស (បានភូវេត)ខេត្តនន្ទបុរី។**

- បទបង្ហាញអំពីការគ្រប់គ្រង រចនាសម្ពន្ធ័របស់មជ្ឈមណ្ឌល និងសកម្មភាពក្នុងការទទួលក្មេងប្រុស ចាប់ពីអាយុ០៦-១៦ឆ្នាំ ដែលសុទ្ធជាកុមារ និងយុវជនមានបញ្ហាក្នុងគ្រួសារក្រីក្រ កំព្រា គ្រួសារចិញ្ចឹមកូនមិនត្រឹមត្រូវ កុមារសុំទាន កុមារដេកតាមចិញ្ចើមថ្នល់ កុមារដែលត្រូវបានគេបោះបង់ចោល កុមារត្រូវបានគេរើសអើង និងកុមារដែលត្រូវបានគេជួញដូរ
- ប្រភពដែលបញ្ជូនកុមារ និងយុវជនទៅកាន់មជ្ឈមណ្ឌលនោះ មាន៤ក្រុមគឺៈ គ្រួសារ ប៉ូលីស មន្ទីរពេទ្យ និងសប្បុរសជន
- ទស្សនកិច្ចតាមផ្នែកជំនាញនីមួយៗដូចជា កន្លែងបណ្តុះបណ្តាលជំនាញកុំព្យូទ័រ សិប្បកម្មកែច្នៃ និងបន្ទប់ពេទ្យ និងសំណួរផ្សេងៗរបស់ភាគីកម្ពុជាពាក់ព័ន្ធភាពរងគ្រោះ និងលទ្ធផលដែលទទួលបានពីការស្តារនីតិសម្បទារបស់កុមារ និងយុវជនរងគ្រោះដែលមានបញ្ហាទាំងនោះ ។

**ថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០១៩**

<u>សកម្មភាពទី១</u>:ដំណើរទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌលគ្រប់គ្រងសុវត្ថិភាពជនរងគ្រោះដោយអំពើជួញដូរមនុស្ស (ផាធុមថានី)ខេត្តផាធុមថានី។

- បទបង្ហាញអំពីរចនាសម្ពន្ធ័គ្រប់គ្រង និងសកម្មភាពរបស់មជ្ឈមណ្ឌលតាមផ្នែកនីមួយៗដែលជាមជ្ឈមណ្ឌលឈានមុខគេក្នុងចំណោមមជ្ឈមណ្ឌលរបស់រដ្ឋាភិបាលទាំង៨ ដោយប្រើប្រាស់ថវិកាជាច្រើនប្រភព(ទាំងរបស់រដ្ឋាភិបាល មូលនិធិ ក្រុមហ៊ុន និងសប្បុរសជន)
- ជនរងគ្រោះជាជនជាតិកម្ពុជាកំពុងស្នាក់នៅមណ្ឌលនេះមានចំនួន១៩នាក់(ក្មេងស្រីចំនួន០៦នាក់)ក្នុងនោះស្ត្រីមានផ្ទៃពោះចំនួន៤នាក់ និងកុមារចំនួន៣នាក់
- គោលដៅរបស់មជ្ឈមណ្ឌលគឺការសង្រ្គោះ ការការពារ ស្តារនីតិសម្បទា និងការអនុវត្តន៍ច្បាប់
- ការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្សគឺអនុលោមទៅតាមច្បាប់ មាត្រា៣៣
- ការគ្រប់គ្រងនិងការការពារគឺជំរុញអោយមានដំណើរការដល់តុលាការដើម្បីឈានទៅដល់ការចាប់ជនល្មើស។
- ជងរងគ្រោះដែលបានជួយសង្រ្គោះរួចហើយ នៅពេលដែលបញ្ចប់វគ្គជំនាញបណ្តុះបណ្តាល គឺពួកគាត់អាចរកការងារធ្វើដោយខ្លួនឯង និងមានការជ្រោមជ្រែងពីមជ្ឈមណ្ឌលដែលមានការសហការជាមួយក្រសួងអភិវឌ្ឍន៍សង្គមមនុស្ស ក្រសួងការងារ និងក្រសួងមហាផ្ទៃ។
- ដំណើរការដំបូងនៃការទទួលជនរងគ្រោះគឺមានការសម្ភាសកំណត់អត្តសញ្ញាណ ពិនិត្យសុខភាព ទាំងខាងផ្លូវចិត្ត កាយ សង្គម ព្រមទាំងរក្សាឯកសារ និងទ្រព្យសម្បត្តិផ្សេងៗរបស់ជនរងគ្រោះ។
-

**ដំណើរការតុលាការ(តស៊ូរឿងក្តី)**

- មណ្ឌលធ្លាប់ដំណើរការក្តី (ជនជាតិថៃមាន៥ករណី ជនជាតិភូមា១៦១ករណី ជនជាតិឡាវ៥ករណី ជនជាតិរូគីនយ៉ា៦ករណី ជនជាតិកម្ពុជា៦៨ករណី(សាក្សីបន្ថែម៩នាក់ហើយទទួលបានសំណងចំនួន៦២នាក់)។
- ជនរងគ្រោះទូកនេសាទមានចំនួន៣៦នាក់ ហើយមេខ្យល់ត្រូវបានចាប់ដាក់គុក និងជនរងគ្រោះទទួលបានសំណងជាង១លានបាត។
- ករណីដំណើរក្តីផ្លូវច្បាប់គិតជាភាគរយ កម្ពុជា២៧% ភូមា៦៥% ឡាវនិងរូគីនយ៉ា២%
- គោលការណ៍សំខាន់គឺជួយជនរងគ្រោះទាំងអស់ដោយមិនរើសអើងពូជសាសន៍។

<u>សកម្មភាពទី២</u>: **ដំណើរទស្សនៈកិច្ចសិក្សានៅមជ្ឈមណ្ឌលបណ្តុះបណ្តាលវិជ្ជាជីវៈស្ត្រី និងគ្រួសារ ខេត្តនន្ទថៈបុរី**

- ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ក្រសួងអភិវឌ្ឍន៍សង្គម និង សន្តិសុខមនុស្ស
- ជាមណ្ឌលដែលជួយស្ត្រីប្រឈមបញ្ហាផ្សេងៗដូចជា បញ្ហាគ្រួសារ ក្រីក្រ ចំណាកស្រុក អំពើហឹង្សា ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះផ្សេងៗទៀត។
- ជាមណ្ឌលដែលគ្រប់គ្រង ជួយជនរងគ្រោះចំនួន១៥ខេត្តនៃភាគកណ្តាលនៃប្រទេសថៃ
- មានការផ្តល់វគ្គបណ្តុះបណ្តាលចំនួន០៧ជំនាញដល់ស្ត្រី គ្រួសារ និង រងគ្រោះដោយអំពើជួញដូរមនុស្ស និងជនងាយរងគ្រោះផ្សេងៗ ដែលមានដូចជា៖ កែសម្ផស្ស កាត់សក់បុរស កុំព្យូទ័រ កាត់ដេរ ការគ្រប់គ្រងសណ្ឋាគារ បង្រៀនធ្វើម្ហូបនិងនំ ម៉ាស្សា។ ការសិក្សាមានរយៈពេល៧២០ម៉ោង ហើយពេលរៀនចប់ពួកគាត់អាចរកការងារធ្វើដោយខ្លួនឯង មណ្ឌលផ្តល់ការស្នាក់នៅដល់សិស្សដែលមានផ្ទះឆ្ងាយ និងផ្តល់អាហារ២ពេល។

### <u>ថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០១៩</u>

- ដំណើរកម្សាន្តទស្សនាប្រាសាទបុរាណ នៅខេត្តអាយុធ្យា ប្រទេសថៃ។

### <u>ថ្ងៃទី០៦ ខែធ្នូ ឆ្នាំ២០១៩</u>

- កិច្ចប្រជុំពិភាក្សាជាមួយតំណាងទីភ្នាក់សហប្រតិបត្តិការអន្តរជាតិថៃ(TICA) អំពីគម្រោងការសាងសង់អគារមជ្ឈមណ្ឌលសំចតទី១ប៉ោយប៉ែត
- ជំនួបសម្តែងការគួរសមជាមួយ**ឯកឧត្តម អ៊ុំ សោភ័ណ្ឌ** អគ្គរាជទូតនៃព្រះរាជាណាចក្រកម្ពុជាប្រចាំព្រះរាជាណាចក្រថៃ។

## IV. លទ្ធផលដែលទទួលបាន:

ក្រោយពីបានបញ្ចប់ទស្សនៈកិច្ចសិក្សារយៈពេល០៦ថ្ងៃនៅព្រះរាជាណាចក្រថៃ ភាគីទាំងពីរបានឯកភាពគ្នាដូចខាងក្រោម៖

- ភាគីថៃសន្យាថានឹងបញ្ចុះបឋមសិលានៅ ឆ្នាំ២០២០ខាងមុខនេះ។
- ភាគីថៃជានាទទួលខុសត្រូវលើការបំពាក់គ្រឿងសង្ហារឹម និងឧបករណ៍ទាំងអស់នៅក្នុងមណ្ឌល។
- ភាគីកម្ពុជា និង ភាគីថៃ បានឯកភាពគ្នាទៅលើការជួយបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈចំនួន៥ប្រភេទ មានដូចជា៖ ១)កែសម្ផស្ស ២)ធ្វើម្ហូបអាហារ និងនំ ៣) ម៉ាស្សា ៤)ជួសជុលម៉ូតូ និងកាត់ដេរសម្លៀកបំពាក់។
- ភាគីថៃ ស្នើអោយភាគីកម្ពុជាបញ្ជូនឈ្មោះមន្ត្រីចំនួន១៨នាក់ដែលចេះជំនាញខ្លះហើយទៅឲ្យខ្លួន នៅខែមករា ឆ្នាំ២០២០ ដើម្បីបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈទាំង៥ប្រភេទខាងលើ នៅពេលខាងមុខឆាប់ៗ។
- ភាគីថៃសន្យាបន្តពង្រឹងសមត្ថភាពដល់មន្ត្រីដែលបានបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងមន្ត្រីផ្នែកគ្រប់គ្រងមជ្ឈមណ្ឌល ដើម្បីឲ្យដំណើរការប្រកបដោយប្រសិទ្ធភាព គុណភាព និងនិរន្តភាពទៅថ្ងៃអនាគត។

- ភាគីទាំងពីរបានសម្រេចកំណត់មន្ត្រីចំនួន០៣រូបធ្វើជាជនបង្គោល សម្រាប់សម្របសម្រួលផ្តល់ព័ត៌មានតាមរយៈ អ៊ីមែល និងតេលេក្រាម អំពីដំណើរការសាងសង់មជ្ឈមណ្ឌល។

អាស្រ័យដូចបានគោរពជម្រាបជូនខាងលើ សូម **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** មេត្តាជ្រាបជារបាយការណ៍ដោយក្តីអនុគ្រោះដ៏ខ្ពង់ខ្ពស់។

សូម **លោកជំទាវ** មេត្តាទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់ពីនាងខ្ញុំ ។

ថ្ងៃចន្ទ១៣កើត ខែមិគសិរ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែធ្នូ គ.ស ២០១៩

**អគ្គលេខាធិការ**

ឧត្តមសេនីយ៍ឯក វេជ្ជ.ប៉ុណ្ណ សំខាន់

បានឃើញ
24/12/19